**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ៣០៥០ មស.គ្រ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
**គោរពជូន**
**ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**កម្មវត្ថុ** : ផ្តល់យោបល់លើសំណើសុំរក្សាប្រាក់បៀវត្ស អតីតភាពការងារសម្រាប់ការឡើងថ្នាក់និងទទួលសោធននិវត្តន៍នៅអង្គភាពដើមរបស់មន្ត្រីរាជការដែលជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**យោង** :
- ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- អនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល
- អនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និង មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា
- អនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- លិខិតលេខ៥៤២/១៦ គ.ជ.ប ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា បន្ទាប់ពីបានពិនិត្យសំណើនិងឯកសារពាក់ព័ន្ធរួចមក ក្រសួងមុខងារសាធារណៈ យល់ថា សំណើរបស់ គ.ជ.ប អាចអនុវត្តអនុលោមតាមមាត្រា២៤ នៃអនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយត្រូវអនុវត្តតាមគោលការណ៍ដែលបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានដូចមានខាងក្រោម៖

១- មន្ត្រីរាជការស៊ីវិលដែលត្រូវបានជ្រើសរើសឱ្យក្លាយជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារនៅគ.ជ.ប ត្រូវទទួលបានតែបៀវត្សមូលដ្ឋាន **ប្រាក់វិភាជន៍គ្រួសារ និងប្រាក់ឧបត្ថម្ភផ្សេងៗ ព្រមទាំងប្រាក់ឧបត្ថម្ភដែលផ្តល់ឱ្យដោយគ.ជ.បប៉ុណ្ណោះ មិនអាចទទួលបានប្រាក់បំណាច់មុខងារនៅស្ថាប័នដើមឡើយ។** ការបើកផ្តល់ប្រាក់បៀវត្សមូលដ្ឋានដល់សាមីខ្លួនគឺអនុវត្តផ្អែកលើ(១)ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្ស

មូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល មាត្រា២១ ចែងថា « មន្ត្រីរាជការដែលស្ថិតនៅក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងនោះ។ មន្ត្រីរាជការដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតអោយជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយទេ។»និង(២)អនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល មាត្រា៤ ចែងថា«ប្រាក់បំណាច់មុខងារ គឺជាប្រាក់បន្ថែមលើបៀវត្សមូលដ្ឋានប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញការងារក្នុងមុខតំណែងតាមរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន។»

២- កន្លងមកដើម្បីជានាប្រសិទ្ធភាពការងារនៃក្រសួង ស្ថាប័ន និងអង្គភាពនានា មន្ត្រីរាជការស៊ីវិលគ្រប់រូបត្រូវបានបែងចែកភារកិច្ចឱ្យទទួលខុសត្រូវរៀងៗខ្លួននិងត្រូវបានគ្រប់គ្រងវត្តមានការងារអនុលោមតាមខ្លឹមសារអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និង អនុក្រឹត្យលេខ៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា ក្នុងន័យនេះ ករណីមន្ត្រីរាជការណាម្នាក់ត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារជាមន្ត្រីជាប់កិច្ចសន្យាក្នុងគ.ជ.ប ត្រូវមានការអនុញ្ញាតជាមុនពីក្រសួង ស្ថាប័ន ឬអង្គភាពសាមីមុនទៅបំពេញការងារនៅគ.ជ.ប ដើម្បីរក្សានិរន្តរភាពនិងប្រសិទ្ធភាពការងារ ព្រមទាំងការបម្រើសេវាសាធារណៈនៅក្រសួង ស្ថាប័នសាមី។

សេចក្តីដូចបានជម្រាបជូនខាងលើសូម ឯកឧត្តមប្រធាន មេត្តាជ្រាបនិងទទួលនូវការគោរពរាប់អានពីខ្ញុំ។ ២៧ 18

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  «ដើម្បីជូនជ្រាប»
- ឯកសារ-កាលប្បវត្តិ

**ពេជ្រ ប៊ុនធិន**